ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពិធីសារស្តីពី
# យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

# COVID-19 Vaccination Campaign Protocol

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

ខែកុម្ភៈ ឆ្នាំ២០២១

## អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តវិធីសាស្ត្រចលនាធនធានសរុបទាំងរាជរដ្ឋាភិបាល និងសង្គម ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ដោយជោគជ័យ។ ប្រទេសកម្ពុជាមិនមានការឆ្លងក្នុងសហគមន៍ជាទ្រង់ទ្រាយធំ គ្មានការស្លាប់និងគ្មានការឆ្លងជំងឺដល់បុគ្គលិកសុខាភិបាលឡើយ។ ជាលទ្ធផលការប៉ះពាល់សុខភាព និងសង្គម ត្រូវបានកាត់បន្ថយជាអប្បបរមាក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងក្នុងភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធ ព្រមទាំងមានការចូលរួមយ៉ាងសកម្មពីសហគមន៍ទាំងមូលផងដែរ។

ទោះយ៉ាងណាក្តី ខណៈពេលដែលជំងឺកូវីដ-១៩ នៅតែជាបញ្ហាសុខភាពសាធារណៈដ៏ធំមួយនៅជុំវិញពិភពលោក គ្មាននរណាម្នាក់មានសុវត្ថិភាពឡើយ រហូតដល់មនុស្សគ្រប់គ្នា មានសុវត្ថិភាព (No One safe until everyone safe)។ វ៉ាក់សាំងដែលមានសុវត្ថិភាព និងប្រសិទ្ធភាពប្រឆាំងនឹងជំងឺកូវីដ-១៩ នឹងជាឧបករណ៍ដ៏សំខាន់ដើម្បីគ្រប់គ្រងការរាតត្បាតរួមជាមួយវិធានការការពារ ដូចជា ការលាងដៃ ការរក្សាគម្លាតសង្គម គម្លាតបុគ្គល ការពាក់ម៉ាស់ និងការជៀសវាងកន្លែងដែលមានមនុស្សកុះករ និងក្នុងទីកន្លែងបិទជិត។ វ៉ាក់សាំងកូវីដ-១៩ នឹងចូលរួមកាត់បន្ថយភាពធ្ងន់ធ្ងរ និងអត្រាស្លាប់ ក្នុងចំណោមប្រជាជនកម្ពុជា ដែលរាជរដ្ឋាភិបាលបានគាំទ្រឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់ត្រៀមទទួលយក និងអនុវត្តការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ដោយជោគជ័យ។ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមអំពាវនាវឱ្យសាធារណជន ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនេះ ដោយឥតគិតថ្លៃ និងដោយស្ម័គ្រចិត្ត ដើម្បីគាំទ្រគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការការពារសុខភាព និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

ក្រសួងសុខាភិបាលបានផលិត " ពិធីសារស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩" ដែលជាសមាសភាគមួយនៃផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និងគោលការណ៍ណែនាំប្រតិបត្តិសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងគោលបំណងជួយដល់គ្រប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសមន្ត្រីអនុវត្តផ្ទាល់សម្រាប់ធ្វើផែនការ ត្រៀមរៀបចំអនុវត្ត និងតាមដានយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា សង្ឃឹមថាគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលមូលដ្ឋាន និងដៃគូអភិវឌ្ឍទាំងអស់នឹងចូលរួមអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ស្របតាមពិធីសារស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នេះឱ្យទទួលបានជោគជ័យ។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា

ទំព័រ

អារម្ភកថា ..................................................................................................... i

១. សេចក្តីផ្តើម ..................................................................................................... ១

២. អំពីវ៉ាក់សាំងកូវីដ-១៩ ..................................................................................................... ១

៣. ការធ្វើផែនការ ..................................................................................................... ២

៤. ប្រជាជនគោលដៅ ..................................................................................................... ២

៥. ការបណ្តុះបណ្តាល ..................................................................................................... ៣

៦. យុទ្ធសាស្ត្រ និងការអនុវត្តចាក់វ៉ាក់សាំង ..................................................................................................... ៤

៧. ការគ្រប់គ្រងបរិក្ខារប្រព័ន្ធត្រជាក់ និងវ៉ាក់សាំង ..................................................................................................... ៨

៨. ការចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព និងសុវត្ថិភាព ..................................................................................................... ៩

៩. ការប្រាស្រ័យទាក់ទងពីហានិភ័យ និងការកៀរគរសង្គម ..................................................................................................... ៩

១០. ការអភិបាល និងតាមដាន ..................................................................................................... ១០

១១. ការពិនិត្យ និងគ្រប់គ្រងហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង ..................................................................................................... ១០

១២. ផែនការបម្រុងជាយថាហេតុ ..................................................................................................... ១២

១៣. ការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ..................................................................................................... ១៣

# ១. សេចក្តីផ្តើម

កូវីដ-១៩ ជាជំងឺឆ្លងបង្កដោយវីរុសកូរ៉ូណា SARS-CoV-2។ ជំងឺកូវីដ-១៩ ពុំធ្លាប់ឃើញលើមនុស្សពីមុនមកទេ។ ករណីដំបូងនៅកម្ពុជាត្រូវបានរកឃើញក្នុងខេត្តព្រះសីហនុ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។ មកត្រឹមថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ មានករណីជំងឺកូវីដ-១៩ ចំនួន ៣៨២ ត្រូវបានរាយការណ៍។ ទោះជាកម្ពុជាមានករណីជំងឺកូវីដ-១៩ ទាប បើធៀបនឹងណ្តាប្រទេសឯទៀតក្នុងពិភពលោកក្តី ក៏ផលប៉ះពាល់នៃជំងឺរាតត្បាតនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចសង្គម ដែលរួមមានការបាត់បង់ការងារនិងប្រាក់ចំណូលសម្រាប់គ្រួសារជាច្រើននិងការរំខានដល់វិស័យពាណិជ្ជកម្ម និងទេសចរណ៍។

ការចាក់វ៉ាក់សាំងជាសមាសធាតុមួយក្នុងចំណោមសមាសធាតុសំខាន់ៗ នៅក្នុងការប្រយុទ្ធនឹងការរាតត្បាតជាសកល។ នៅក្នុងកាលៈទេសៈនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ការបន្តអនុវត្តវិធានការបង្ការការឆ្លងនៃជំងឺកូវីដ-១៩ ដូចជាការពាក់ម៉ាស់ អនាម័យដៃ និងគម្លាតរូបវ័ន្តមានសារៈសំខាន់ជាសារវ័ន្ត។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាប្តេជ្ញាផ្តល់វ៉ាក់សាំងកូវីដ-១៩ ដល់ប្រជាពលរដ្ឋ ១០លាននាក់ សំដៅសង្គ្រោះអាយុជីវិតប្រជាពលរដ្ឋ និងបញ្ឈប់ការរំខានសង្គមនិងសេដ្ឋកិច្ច។ ដើម្បីសំរេចគោលដៅនេះ រាជរដ្ឋាភិបាលប្រើប្រាស់យន្តការជាច្រើន ដើម្បីទទួលបានវ៉ាក់សាំងកូវីដ-១៩ រួមបញ្ចូលទាំងយន្តការដៃគូសកល សម្របសម្រួលនិងជំរុញការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ (COVAX Facility) និង ការចរចារទ្វេរភាគីជាមួយប្រទេសផលិតវ៉ាក់សាំង។ COVAX Facility នឹងផ្តល់វ៉ាក់សាំងកូវីដ-១៩ ដើម្បីគ្របដណ្តប់ប្រមាណ ២០% នៃប្រជាជនសរុបសម្រាប់ក្រុមគោលដៅអាទិភាព។ កម្ពុជានឹងទទួលបានវ៉ាក់សាំង ១លានដូស ពីសាធារណរដ្ឋប្រជាមានិតចិន។ រាជរដ្ឋាភិបាលគ្រោងទិញវ៉ាក់សាំងបន្ថែមទៀតសម្រាប់ប្រជាជនគោលដៅដែលនៅសេសសល់។

ពិធីសារនេះនឹងជួយប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត អ្នកគ្រប់គ្រងមូលដ្ឋានសុខាភិបាល និងមន្ត្រីសុខាភិបាល ដើម្បីត្រៀមរៀបចំ ធ្វើផែនការ អនុវត្ត និងតាមដានយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅក្នុងប្រទេសប្រកបដោយប្រសិទ្ធភាព។

# ២. អំពីវ៉ាក់សាំងកូវីដ-១៩

## ២.១. វ៉ាក់សាំងកូវីដ-១៩

វ៉ាក់សាំងកូវីដ-១៩ ជាវ៉ាក់សាំងដែលទើបតែរកឃើញនិងផលិតថ្មី សម្រាប់បង្ការទល់នឹងវីរុស SARS-CoV-2 ដែលបង្កឱ្យមានជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរ។ អ្នកស្រាវជ្រាវនិងអ្នកផលិតវ៉ាក់សាំងកូវីដ-១៩ ប្រើប្រាស់បច្ចេកវិទ្យាច្រើនប្រភេទខុសគ្នា ដើម្បីបង្កើតវ៉ាក់សាំងកូវីដ-១៩ នេះឡើង ដូចជាការប្រើប្រូតេអ៊ីន អាស៊ីតរីបូនុយក្លេអ៊ីក ឬវីរុសអសកម្ម។ យោងតាមទិន្នន័យដែលបានបោះពុម្ពផ្សាយអំពីលទ្ធផលសិក្សាស្រាវជ្រាវបង្ហាញថា វ៉ាក់សាំងកូវីដ-១៩ មានសុវត្ថិភាពនិងមានប្រសិទ្ធភាព។ វ៉ាក់សាំងមួយចំនួនកំពុងស្ថិតក្នុងនិតិវិធីស្នើសុំការអនុម័តពីអង្គការសុខភាពពិភពលោក ដើម្បីបញ្ចូលទៅក្នុងបញ្ជីប្រើប្រាស់ក្នុងគ្រាអាសន្ន (EUL)។

## ២.២. ការចាក់វ៉ាក់សាំងកូវីដ-១៩

ត្រូវប្រាកដថា បានជ្រើសរើសកម្រិតដូស របៀបចាក់ និងកន្លែងចាក់ត្រឹមត្រូវ។ ជាទូទៅសម្រាប់វ៉ាក់សាំងកូវីដ-១៩៖

- កម្រិតដូស៖
  - 0.៥មល សម្រាប់វ៉ាក់សាំងភាគច្រើន ដែលត្រូវរក្សាទុកក្នុងសីតុណ្ហភាព +២ ទៅ +៨ អង្សាសេ និង
  - 0.៣មល សម្រាប់វ៉ាក់សាំង ដែលត្រូវរក្សាទុកក្នុងសីតុណ្ហភាព -៦០ ទៅ -៨០ អង្សាសេ។
- កន្លែងចាក់៖ ចាក់សាច់ដុំដែលតូអ៊ីដ នៅដើមដៃស្តាំ។
- របៀបចាក់៖ សាច់ដុំដើមដៃស្តាំ




រូបភាពទី១៖ ការចាក់សាច់ដុំវ៉ាក់សាំងកូវីដ-១៩

សម្រាប់វ៉ាក់សាំងភាគច្រើនដែលចរាចរនៅទីផ្សារ ឬកំពុងត្រូវបានផលិត ត្រូវចាក់ពីរដូស។ សម្រាប់វ៉ាក់សាំងដែលត្រូវចាក់ពីរដូស ផលិតផលវ៉ាក់សាំងតែមួយគួរត្រូវបានប្រើសម្រាប់បុគ្គលតែម្នាក់។

មិនត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ដល់អ្នកធ្លាប់មានប្រតិកម្មអាលែហ្សីធ្ងន់ធ្ងរទេ។ អ្នកដែលបានទទួលវ៉ាក់សាំងកូវីដ-១៩ គួរត្រូវបានតាមដានក្នុងរយៈពេលយ៉ាងតិច ៣០នាទី ដើម្បីរកមើលប្រតិកម្មធ្ងន់ធ្ងរដែលមិនអាចស្មានដឹងជាមុន នៅមូលដ្ឋានសុខាភិបាល ឬនៅកន្លែងចាក់វ៉ាក់សាំង មុនពេលត្រឡប់ទៅវិញ។

# ៣. ការធ្វើផែនការ

## ៣.១. ការចុះឈ្មោះប្រជាជនចំណុចទាំងអស់

ក្រសួងសុខាភិបាលនឹងប្រកាសពីការចុះឈ្មោះជាមុនដល់ប្រជាពលរដ្ឋទាំងអស់ និងជនបរទេសដែលស្នាក់នៅនិងធ្វើការក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានអាយុចាប់ពី ១៦ ឆ្នាំឡើងទៅ ឱ្យធ្វើការចុះឈ្មោះដោយប្រើកម្មវិធីចុះឈ្មោះអនឡាយ។ ការចុះឈ្មោះអាចត្រូវបានធ្វើដោយខ្លួនឯង ឬដោយរដ្ឋបាលមូលដ្ឋាននិងមណ្ឌលសុខភាព រួមទាំងគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ឬដោយសាច់ញាតិ ឬមិត្តភ័ក្ត្រ។ ក្រសួងសុខាភិបាលនឹងផ្តល់រយៈមួយសម្រាប់ការចុះឈ្មោះ (ដែលប៉ាន់ស្មានពី១៥ថ្ងៃទៅ ៣០ ថ្ងៃធ្វើការ) ដើម្បីបានប្រជាពលរដ្ឋ ១០ លាននាក់។ ក្រុមប្រជាជនគោលដៅដែលបានចុះឈ្មោះរួច នឹងត្រូវបានណែនាំឱ្យទៅទទួលវ៉ាក់សាំងនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ ក្រុមប្រជាជនគោលដៅអាយុ ១៦-៦៤ ឆ្នាំ ដែលមានជំងឺរ៉ាំរ៉ៃប្រចាំកាយត្រូវបញ្ជាក់ពីនៅក្នុងពេលចុះបញ្ជីដោយគូសធីក នៅក្នុងកម្មវិធីចុះឈ្មោះ ទោះចុះឈ្មោះដោយខ្លួនឯង ឬដោយស្មៀនឃុំ។

## ៣.២. ការធ្វើផែនការលម្អិត

ផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នឹងតម្រូវឱ្យមានផែនការ និងការត្រៀមរៀបចំនៅគ្រប់លំដាប់ថ្នាក់។ គម្រូផែនការលម្អិតត្រូវបានរៀបចំដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងត្រូវបានចែកចាយទៅថ្នាក់ក្រោមជាតិ។ ផែនការលំអិតត្រូវមានធនធានដែលត្រូវការ ដូចជាធនធានមនុស្ស ហិរញ្ញវត្ថុ និងសម្ភារៈ-បរិក្ខារ សេវាចាក់វ៉ាក់សាំងសម្រាប់ក្រុមប្រជាជនគោលដៅ។ ផែនការលម្អិតនឹងត្រូវបានដឹកនាំធ្វើដោយមន្ទីរពេទ្យ ដោយមានការគាំទ្រពីអ្នកគ្រប់គ្រងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនៅថ្នាក់ក្រោមជាតិ។ ជាធម្មតាផែនការលម្អិតត្រូវបានបញ្ចប់យ៉ាងយូរបំផុត ៥ថ្ងៃ និងផ្ញើជូនកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្រោយពីបានទទួលការជូនដំណឹងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ។

អ្នកពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់គួរមានការពិចារណាខ្ពស់ថា មិនគួរឱ្យមានការរាំងស្ទះដល់សេវាផ្តល់ថ្នាំបង្ការជាប្រចាំដោយសារយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ទេ។

# ៤. ប្រជាជនគោលដៅ

វត្ថុបំណងចំបងនៃការចាក់វ៉ាក់សាំងកូវីដ-១៩ គឺការកាត់បន្ថយភាពធ្ងន់ធ្ងរនៃជំងឺនិងមរណភាព ការរក្សាមុខងារ-សេវាសុខាភិបាល និងសេវាសារវ័ន្តផ្សេងទៀត និងកាត់បន្ថយឱ្យនៅអប្បបរិមាការរំខានដល់សង្គម និងសេដ្ឋកិច្ច។

អនុលោមតាមអនុសាសន៍នៃក្រុមប្រឹក្សាអ្នកឯកទេសយុទ្ធសាស្រ្តផ្តល់ថ្នាំបង្ការ និងវ៉ាក់សាំងនៃអង្គការសុខភាពពិភពលោក ភាពមានកម្រិតនៃការផ្គត់ផ្គង់វ៉ាក់សាំងជាសកល បរិបទកម្ពុជា និងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាលបានកំណត់ក្រុមប្រជាជនគោលដៅអាទិភាពនិងក្រុមគោលដៅផ្សេងទៀតដែលនឹងត្រូវទទួលវ៉ាក់សាំងកូវីដ-១៩ នៅឆ្នាំ២០២១។ ដោយហេតុថា កម្ពុជាទំនងជាទទួលវ៉ាក់សាំងកូវីដ-១៩ ជាដំណាក់ៗ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នឹងត្រូវធ្វើឡើងជាពីរដំណាក់កាល រហូតគ្របដណ្តប់ក្រុមគោលដៅទាំងអស់ដែលបានចុះបញ្ជី។ ការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងមិនគិតថ្លៃ។

តារាងទី ១៖ ក្រុមគោលដៅ ប្រជាជនគោលដៅ (ប៉ាន់ប្រមាណ) និងដំណាក់កាល

| ល.រ | ប្រជាជនគោលដៅ | ប្រជាជនគោលដៅសរុប | ដំណាក់កាល I | ដំណាក់កាល II | ដំណាក់កាល III |
|---|---|---|---|---|---|
| ១ | មន្ត្រីថែទាំសុខភាពគ្រប់ថ្នាក់ | ៣០,០០០ | ១០០% | | |
| ២ | កងកម្លាំងប្រដាប់អាវុធជួរមុខ នគរបាល | ៣០០,០០០ | ១០០% | | |
| ៣ | មន្ត្រីរាជការស៊ីវិលជួរមុខ | ១៦៩,៧២១ | ១០០% | | |
| ៤ | ជនបង្គោលសហគមន៍និងអ្នកស្ម័គ្រចិត្ត | ៥០,០៧៤ | | ១០០% | |
| ៥ | ជនចាស់ជរា ចាប់អាយុ៦៥ឆ្នាំឡើងទៅ | ៩៤៤,៩៣២ | | ៥០%(៤៧២,៤៦៦) | ៥០%(៤៧២,៤៦៦) |
| ៦ | មនុស្សពេញវ័យអាយុ ១៦-៦៤ឆ្នាំ | ៧,៦៨១,៩៩៨ | | ៥០%(៣,៨២៥,៩៩៩) | ៥០%(៣,៨២៥,៩៩៩) |
| ៧ | ក្រុមកម្មករ | | | | |
| ៧.១ | អ្នករត់ម៉ូតូឌុប ម៉ូតូកង់បី ស៊ីក្លូ និងផ្សេងៗ | ១២០,០០០ | | ១០០% | |
| ៧.២ | កម្មករប្រមូលសម្រាម និងផ្សេងៗ | ២០,០០០ | | ១០០% | |
| ៧.៣ | កម្មកររោងចក្រកាត់ដេរ និងការដ្ឋានសាងសង់ | ៦២១,២៧៥ | | ៥០%(៣១០,៦៣៧) | ៥០%(៣១០,៦៣៧) |
| ៨ | ជនបរទេសដែលរស់នៅនិងប្រកបការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា | ៥០,០០០ | ជនបរទេសអាយុពី ១៦ ឆ្នាំឡើងទៅនឹងទទួលការចាក់វ៉ាក់សាំងទៅតាមប្រភេទក្រុមគោលដៅដូចបានបែងចែកក្នុងតារាងនេះ | | |
| | សរុប | ៩,៩៥៨,០០០ | ៤៩៩,៧២១ | ៤,៧២៤,១៧៧ | ៤,៦៣៤,១០៣ |

# ៥. ការបណ្តុះបណ្តាល

កម្មវិធីជាតិផ្តល់ថ្នាំបង្ការ រួមនឹងក្រុមបច្ចេកព័ត៌មានវិទ្យារបស់ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍដែលពាក់ព័ន្ធនានានឹងធ្វើការបណ្តុះបណ្តាល និងការតម្រង់ទិសដូចខាងក្រោម៖

## វគ្គបណ្តុះបណ្តាលពិសេសសម្រាប់ក្រុមមន្ទីរពេទ្យជាតិ

កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងធ្វើការបណ្តុះបណ្តាលដោយឡែករយៈពេលបីថ្ងៃ អំពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដល់ក្រុមចាក់វ៉ាក់សាំង និងមន្ត្រីព័ត៌មានវិទ្យា នៃមន្ទីរពេទ្យជាតិទាំងអស់ដែលត្រូវបានជ្រើសរើសអំពី៖

- បច្ចេកទេសចាក់វ៉ាក់សាំងកូវីដ-១៩ ការរក្សាទុកវ៉ាក់សាំង និងការរៀបចំនិងគ្រប់គ្រងប៉ុស្តិ៍ចាក់វ៉ាក់សាំង
- ការតាមដានផលបន្ទាប់បន្សំនៃវ៉ាក់សាំង និងការគ្រប់គ្រងហេតុការណ៍ធ្ងន់ធ្ងរដែលកើតមានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ បើមាន (មើលតួនាទី-ភារៈកិច្ចនៃប្រធានក្រុមចាក់វ៉ាក់សាំង)
- ក្រុមមន្ត្រីព័ត៌មានវិទ្យា ដោយមានការគាំទ្រពីគ្រូបង្គោលនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ នឹងធ្វើការបណ្តុះបណ្តាលរយៈពេលមួយថ្ងៃ អំពីរបៀបប្រើកម្មវិធីក្នុងអំឡុងពេលចាក់វ៉ាក់សាំង ដូចជា៖ ការស្វែងរកឈ្មោះអតិថិជនដែលបានចុះឈ្មោះរួចនៅក្នុងកម្មវិធី ការបញ្ចូលលេខកូដប័ណ្ណចាក់វ៉ាក់សាំងទៅក្នុងព័ត៌មានលម្អិតរបស់អតិថិជននៅក្នុងកម្មវិធីដោយការស្កែន កត់ត្រាកាលបរិច្ឆេទចាក់វ៉ាក់សាំង (ដូសទី១ និងទី២) និងកាលបរិច្ឆេទណាត់លើកក្រោយ ក៏ដូចជារបៀបទាញយករបាយការណ៍ប្រចាំថ្ងៃនៃកម្មវិធី។

## វគ្គបណ្តុះបណ្តាលគ្រូបង្គោល

កម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលរយៈពេល ៣ថ្ងៃ៖

- សិក្ខាកាម៖ មន្ត្រីកម្មវិធីផ្តល់ថ្នាំបង្ការ និងមន្ត្រីព័ត៌មានវិទ្យានៃមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងមន្ត្រីកម្មវិធីផ្តល់ថ្នាំបង្ការនៃស្រុកប្រតិបត្តិ
- ខ្លឹមសារ៖
  - យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
  - ការធ្វើផែនការលំអិត

- តួនាទី-ភារៈកិច្ចក្រុមចាក់វ៉ាក់សាំង រួមទាំងការតាមដានផលបន្ទាប់បន្សំនៃវ៉ាក់សាំង និងការគ្រប់គ្រងហេតុការធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង បើមាន (មើលតួនាទី-ភារៈកិច្ចក្រុមចាក់វ៉ាក់សាំង) និង
- ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ចុះឈ្មោះ និងកត់ត្រាការចាក់វ៉ាក់សាំង។

ក្រុមមន្ត្រីព័ត៌មានវិទ្យានៃក្រសួងសុខាភិបាលនឹងធ្វើការបណ្តុះបណ្តាលរយៈពេលមួយថ្ងៃ៖

- សិក្ខាកាម៖ មន្ត្រីកម្មវិធីផ្តល់ថ្នាំបង្ការ និងមន្ត្រីព័ត៌មានវិទ្យានៃមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងមន្ត្រីកម្មវិធីផ្តល់ថ្នាំបង្ការនៃស្រុកប្រតិបត្តិ
- ខ្លឹមសារ៖
  - របៀបប្រើកម្មវិធីសម្រាប់ការចុះឈ្មោះមុនយុទ្ធនាការចាក់វ៉ាក់សាំង
  - របៀបប្រើកម្មវិធីសម្រាប់ការកត់ត្រាការចាក់វ៉ាក់សាំងក្នុងអំឡុងពេលយុទ្ធនាការដូចជា៖ ការស្វែងរកឈ្មោះអតិថិជនដែលបានចុះឈ្មោះរួចនៅក្នុងកម្មវិធី ការបញ្ចូលលេខកូដប័ណ្ណចាក់វ៉ាក់សាំងទៅក្នុងព័ត៌មានលម្អិតរបស់អតិថិជននៅក្នុងកម្មវិធីដោយការស្កេន កត់ត្រាកាលបរិច្ឆេទចាក់វ៉ាក់សាំង (ដូសទី១ និងទី២) និងកាលបរិច្ឆេទណាត់លើកក្រោយ ក៏ដូចជារបៀបទាញយករបាយការណ៍ប្រចាំថ្ងៃនៃកម្មវិធី។

### វគ្គបណ្តុះបណ្តាលមន្ទីរពេទ្យខេត្ត/ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព និងវគ្គតម្រង់ទិស

- ក្រោយការបណ្តុះបណ្តាលគ្រូបង្គោល៖
  - គ្រូបង្គោលមន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិ ដោយមានការគាំទ្រពីកម្មវិធីជាតិផ្តល់ថ្នាំបង្ការនឹងធ្វើការបណ្តុះបណ្តាលរយៈពេល ២ថ្ងៃ ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និងការធ្វើផែនការលំអិតដល់អ្នកចាក់វ៉ាក់សាំងមកពីមន្ទីរមន្ទីរពេទ្យរាជធានី-ខេត្ត មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព។
  - មន្ត្រីបច្ចេកទេសព័ត៌មានវិទ្យា ដោយមានការគាំទ្របច្ចេកទេសពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត នឹងធ្វើការបណ្តុះបណ្តាលបន្តរយៈពេល១ថ្ងៃ អំពីរបៀបចុះឈ្មោះជាមុន ដល់ស្មៀនឃុំ និងសមាជិកអាជ្ញាធរមូលដ្ឋានដែលពាក់ព័ន្ធផ្សេងទៀត មុននឹងចាប់ផ្តើមអនុវត្តការចុះឈ្មោះមុនចាក់វ៉ាក់សាំង។
- មន្ត្រីមណ្ឌលសុខភាពនឹងធ្វើការតម្រង់ទិសដល់ជនបង្គោលសហគមន៍ និងអ្នកស្ម័គ្រចិត្ត។

# ៦. យុទ្ធសាស្ត្រ និងការអនុវត្តចាក់វ៉ាក់សាំង

យុទ្ធសាស្ត្រចាក់វ៉ាក់សាំងមានប្រសិទ្ធភាព ជាគន្លឹះជោគជ័យនៃផែនការជាតិស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។ យុទ្ធនាការនេះនឹងចាប់ផ្តើមពីដំណាក់កាលទី១ រួចបន្តទៅដំណាក់បន្តបន្ទាប់ រហូតគ្របដណ្តប់ប្រជាជន ១០លាននាក់។

## ៦.១. ដំណាក់កាលអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

ប្រជាជនគោលដៅនៃគ្រប់ដំណាក់កាលទាំងអស់នឹងត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ នៅមូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែក ស្រុកប្រតិបត្តិ)។ ប្រជាជនគោលដៅដែលបានចុះឈ្មោះរួចនឹងត្រូវបានណែនាំឱ្យ ទៅចាក់វ៉ាក់សាំងកូវីដ-១៩ នៅមូលដ្ឋានសុខាភិបាលដែលជិតបំផុត។ ការជូនដំណឹងពីកាលបរិច្ឆេទចាក់វ៉ាក់សាំងដូសទី១ និង ទី២នឹងធ្វើឡើងតាមកម្មវិធីអនឡាញ។ ការយល់ដឹងពីសារៈប្រយោជន៍និងហានិភ័យនៃវ៉ាក់សាំងគឺជាទិដ្ឋភាពស្នូល ហើយអតិថិជននឹងត្រូវបានស្នើសុំឱ្យផ្តិតមេដៃនៅលើលិខិតយល់ព្រមចាក់វ៉ាក់សាំង។ ប្រជាជនគោលដៅនៃដំណាក់កាលទី១ នឹងត្រូវបានចាក់វ៉ាក់សាំងព្រមពេលជាមួយគ្នាទូទាំងប្រទេស។ និតិវិធីនៃការចាក់វ៉ាក់សាំងនេះនឹងត្រូវបានអនុវត្តសម្រាប់ដំណាក់កាលផ្សេងទៀតដែរ។

## ៦.២. កាលវិភាគនៃការចាក់វ៉ាក់សាំងកូវីដ-១៩

- ដំណាក់កាលទី១៖ ដូសទី១ និងដូសទី២
- ដំណាក់កាលទី២៖ ដូសទី១ និង ដូសទី២
- ដំណាក់កាលទី៣៖ ដូសទី១ និង ដូសទី២

- ដំណាក់កាលផ្សេងៗទៀតនឹងត្រូវដំណើរការ បើចាំបាច់។

## ៦.៣. សមាសភាពក្រុមចាក់វ៉ាក់សាំងកូវីដ-១៩

### ក្រុមចាក់វ៉ាក់សាំងនៅតាមទីតាំងចាក់

ជាទូទៅគេរំពឹងថា កន្លែងចាក់វ៉ាក់សាំងនីមួយៗនឹងអាចចាក់វ៉ាក់សាំងដល់ប្រជាជនគោលដៅអប្បបរមាចំនួន ១០០នាក់ក្នុងមួយថ្ងៃ។ ផែនការបច្ចុប្បន្នរួមមាន៖

- ប៉ុស្តិ៍ចាក់វ៉ាក់សាំងចំនួន ៥ រួមនឹងភ្នាក់ងារសន្តិសុខ នៅក្នុងមន្ទីរពេទ្យជាតិដែលបានកំណត់នីមួយៗ
- ប៉ុស្តិ៍ចាក់វ៉ាក់សាំងចំនួន ៥ រួមនឹងភ្នាក់ងារសន្តិសុខ ក្នុងមន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែក ស្រុកប្រតិបត្តិនីមួយៗ

### សមាសភាពក្រុមអ្នកចាក់វ៉ាក់សាំង

- ជំនួយការអ្នកចាក់វ៉ាក់សាំងចំនួនពីរនាក់៖ ស្ទង់កម្តៅអតិថិជន បាញ់អាកុលសម្អាតដៃជូនពួកគាត់ និងត្រួតពិនិត្យមើលការពាក់ម៉ាស់
- អនុប្រធានក្រុមមួយនាក់ និងជំនួយការប្រធានក្រុមមួយនាក់៖ ពិនិត្យស្ថានភាព និងប្រវត្តិជំងឺអតិថិជន រួមទាំងប្រតិកម្មអាលែហ្ស៊ីដែលធ្លាប់ដឹង
- អ្នកកត់ត្រាចំនួនពីរនាក់ (ប្រើកម្មវិធីអនឡាញដើម្បីស្វែងរកឈ្មោះអតិថិជន និងកត់ត្រាការចាក់វ៉ាក់សាំង)
- អ្នកចាក់វ៉ាក់សាំងចំនួន២នាក់
- ប្រធានក្រុមចំនួន ១នាក់ (អ្នកអភិបាលក្រុម)។

## ៦.៤. ការរៀបចំទីកន្លែង/ប៉ុស្តិ៍ចាក់វ៉ាក់សាំង

សុវត្ថិភាពទាំងបុគ្គលិកថែទាំសុខភាព និងប្រជាជនគោលដៅនៅកន្លែងចាក់វ៉ាក់សាំងមានសារៈសំខាន់ណាស់។

- បន្ទប់ដាក់លាក់គួរតែត្រូវបានកំណត់សម្រាប់ជាទីកន្លែងចាក់វ៉ាក់សាំង
  - ទោះប៉ុស្តិ៍ចាក់វ៉ាក់សាំងទាំងអស់នៅក្នុងបន្ទប់តែមួយក្តី គួរមានចម្ងាយគ្រប់គ្រាន់ពីប៉ុស្តិ៍មួយទៅប៉ុស្តិ៍មួយ
  - គម្លាតពីអតិថិជនម្នាក់ទៅអតិថិជនម្នាក់គួរត្រូវបានសម្គាល់ដោយសញ្ញាដាក់លើកម្រាល
  - បន្ទប់ចាក់វ៉ាក់សាំងគួរតែត្រូវបានសម្អាតនិងមានខ្យល់ចេញចូលល្អ។ អាចធ្វើបាន គួររៀបចំឱ្យមានច្រកចេញ និងច្រកចូលដាច់ដោយឡែកពីគ្នា។
  - បន្ទប់ចាក់វ៉ាក់សាំងចាំបាច់ត្រូវមានកន្លែងរង់ចាំ សម្រាប់សង្កេតស្ថានភាពអតិថិជនដែលចាក់វ៉ាក់សាំងរួច យ៉ាងតិច ៣០នាទី។
- គោលការណ៍ណែនាំស្តីពីការបង្ការ និងការត្រួតពិនិត្យការចម្លងរោគសម្រាប់មូលដ្ឋានព្យាបាលនិងថែទាំសុខភាព របស់ក្រសួងសុខាភិបាល និងគោលការណ៍ណែនាំសម្រាប់អន្តរាគមន៍មិនមែនឱសថគួរត្រូវបានអនុវត្តសម្រាប់ទាំងប្រជាជនគោលដៅនិងអ្នកផ្តល់សេវា (ដូចជាការពាក់ម៉ាស់ អនាម័យដៃ និងការរក្សាគម្លាតរូបវន្ត)។
- តម្រូវការអប្បបរមានៃសម្ភារៈ៖
  - សាប៊ូ
  - អនាម័យដៃ
  - ម៉ាស់មុខ
  - ថង់ធំសំរាប់សំរាម

## ៦.៥. តួនាទី និងការទទួលខុសត្រូវរបស់ក្រុមចាក់វ៉ាក់សាំង

### ជំនួយការអ្នកចាក់វ៉ាក់សាំង

- រក្សាចរន្តនៃអតិថិជន ដោយធានាពីគម្លាតរូបវន្តយ៉ាងតិច ១.៥ម
- រក្សាភាពស្អាតបាតនៃប៉ុស្តិ៍ចាក់វ៉ាក់សាំង
- បាញ់អាកុលឬជែល ជូនអតិថិជនសម្អាតដៃ
- ស្ទង់សីតុណ្ហភាពអតិថិជន និងប្រាកដថាគាត់បានពាក់ម៉ាស់

- បើអតិថិជនមានគ្រុនក្ដៅ (សីតុណ្ហភាពចាប់ពី ៣៨ អង្សាសេឡើងទៅ) បញ្ជូនទៅត្រួតពិនិត្យបន្តនៅមន្ទីរពេទ្យ
- បើអតិថិជនមិនពាក់ម៉ាស់ទេ ផ្ដល់ម៉ាស់ជូនគាត់ពាក់ និងប្រាកដថា គាត់បានពាក់ត្រឹមត្រូវ។

**អនុប្រធានក្រុម និងជំនួយការប្រធានក្រុមចាក់វ៉ាក់សាំង**

- ពិនិត្យស្ថានភាព និងប្រវត្តិជំងឺ រួមទាំងប្រតិកម្មអាលែហ្ស៊ីដែលធ្លាប់ដឹង គ្រប់អតិថិជនទាំងអស់
- កត់ត្រាប្រវត្តិជំងឺអតិថិជនទៅក្នុងទម្រង់ដែលមានស្រាប់របស់មន្ទីរពេទ្យ
- ជម្រាបជូនប្រធានក្រុមភ្លាម បើអតិថិជនណាម្នាក់មានប្រតិកម្មអាលែហ្ស៊ីដែលធ្លាប់ដឹងពីមុនមក។

**អ្នកកត់ត្រា** ( **ប្រើប្រាស់** Online Application )

- ផ្ទៀងផ្ទាត់ឈ្មោះអតិថិជនក្នុងបញ្ជីសម្រង់ក្រុមគោលដៅ តាម Online Application
- ជម្រាបជូនអតិថិជនពីប្រតិកម្មដែលអាចមាននៃវ៉ាក់សាំងកូវីដ-១៩ និងសុំការយល់ព្រមចាក់វ៉ាក់សាំងពីគាត់៖
  - បើអតិថិជន **យល់ព្រម** ចាក់វ៉ាក់សាំងកូវីដ-១៩ គូសធីក " ☑" ក្នុងប្រអប់ "**បាទ-ចាស**" ក្នុងលិខិតយល់ព្រម រួចសុំឱ្យគាត់ផ្ដិតមេដៃលើលិខិតយល់ព្រម
  - បើអតិថិជន **មិនយល់ព្រម** ចាក់វ៉ាក់សាំងកូវីដ-១៩ គូសធីក " ☑" ក្នុងប្រអប់ "**ទេ**" ក្នុងលិខិតយល់ព្រម រួចសុំឱ្យគាត់ផ្ដិតមេដៃលើលិខិតយល់ព្រម
- ស្កេនឬកត់លេខបណ្ណចាក់វ៉ាក់សាំងទៅក្នុងឯកសារព័ត៌មានលម្អិតរបស់អតិថិជន
- កត់ឈ្មោះអតិថិជន ឈ្មោះវ៉ាក់សាំង កាលបរិច្ឆេទចាក់វ៉ាក់សាំង និងថ្ងៃណាត់លើកក្រោយលើបណ្ណចាក់វ៉ាក់សាំង
- ប្រាប់អតិថិជនឱ្យទៅជួបអ្នកចាក់ ដើម្បីចាក់វ៉ាក់សាំង
- ចេញបណ្ណចាក់វ៉ាក់សាំង និងប្រគល់បណ្ណចាក់វ៉ាក់សាំងទៅអតិថិជនបន្ទាប់ពីគាត់បានទទួលវ៉ាក់សាំងរួច
- រំលឹកដល់អតិថិជនពីកាលបរិច្ឆេទសម្រាប់ការចាក់វ៉ាក់សាំងលើកទី២
- ផ្ញើលិខិតយល់ព្រមចាក់វ៉ាក់សាំងដែលមានស្នាមមេដៃរបស់អតិថិជន របាយការណ៍វ៉ាក់សាំង-សំភារៈ ប្រចាំថ្ងៃទៅអ្នកគ្រប់គ្រងមូលដ្ឋានសុខាភិបាល។

**អ្នកចាក់វ៉ាក់សាំង**

- ប្រមូលវ៉ាក់សាំង និងសម្ភារៈសម្រាប់យុទ្ធនាការ ប្រចាំថ្ងៃឱ្យបានទាន់ពេល ទៅតាមផែនការលំអិត។
- ធានាការរៀបចំកន្លែងចាក់វ៉ាក់សាំងឱ្យបានត្រឹមត្រូវ។
- ធានាថា រាល់វិធានការប្រុងប្រយ័ត្នជាមុនត្រូវបានអនុវត្ត។
- ធានាឱ្យបាននូវការអនុវត្តចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព។
- ចាក់វ៉ាក់សាំងឱ្យអតិថិជន-ក្រុមប្រជានគោលដៅដែលបានកំណត់
- ប្រាស្រ័យទាក់ទងជាមួយប្រជាជនគោលដៅស្តីពីផលរំខានដែលអាចមាន និងសូមគាត់ឱ្យអង្គុយនៅកន្លែងរង់ចាំរយៈពេល ៣០នាទីបន្ទាប់ពីចាក់វ៉ាក់សាំង ដើម្បីតាមដាន។
  - ជម្រាបគាត់ថា បើមានសញ្ញាណាមួយកើតឡើង សូមឱ្យគាត់ប្រាប់ជាបន្ទាន់
  - ពិនិត្យព្យាបាលភ្លាមបើជាបញ្ហាតិចតួច ឬបញ្ជូនជាបន្ទាន់ទៅមន្ទីរពេទ្យ
- ទាក់ទងជាមួយអ្នកគ្រប់គ្រងមូលដ្ឋានសុខាភិបាលឱ្យបានទាន់ពេល បើមានកង្វះខាតវ៉ាក់សាំង
- ធានាថា កន្លែងចាក់វ៉ាក់សាំងមានភាពស្អាតបាតជានិច្ច។

**ប្រធានក្រុម**

- ប្រធានក្រុមនឹងត្រូវបានជ្រើសរើសដោយស្រុកប្រតិបត្តិ និងត្រូវអភិបាល និងតាមដានក្រុមចាក់វ៉ាក់សាំង
- ក្រុមនេះត្រូវអភិបាលមន្ទីរពេទ្យមួយ ឬមណ្ឌលសុខភាពមួយ និងធានាថាវ៉ាក់សាំង និងការផ្គត់ផ្គង់ វិធានការបង្ការ និងសុវត្ថិភាពក្នុងការចាក់វ៉ាក់សាំងនៅតាមប៉ុស្តិ៍ចាក់វ៉ាក់សាំងនីមួយៗ

- តាមដានសភាពទូទៅរបស់អតិថិជនដែលអង្គុយនៅកន្លែងរង់ចាំក្រោយចាក់វ៉ាក់សាំងរួចយ៉ាងតិច ៣០នាទី។ បើមានហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង បញ្ជូនអតិថិជនជាបន្ទាន់ទៅផ្នែកសង្គ្រោះបន្ទាន់ និងរាយការណ៍ជូនទៅទៅអ្នកសម្របសម្រួលរាជធានី-ខេត្ត
- ប្រាស្រ័យទាក់ទងជាមួយអ្នកសម្របសម្រួលមន្ទីរសុខាភិបាល និងកម្មវិធីជាតិ ដើម្បីការគាំទ្រដែលត្រូវការ។

## ៦.៦. តួនាទី និងការទទួលខុសត្រូវរបស់ស្រុកប្រតិបត្តិ

- ប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការសម្រាប់ប៉ុស្តិ៍នីមួយៗ៖
  - បើការចុះឈ្មោះត្រូវបានធ្វើចប់សព្វគ្រប់ក្នុងតំបន់គ្របដណ្តប់របស់ខ្លួន ប៉ាន់ប្រមាណចំនួនដូសដោយប្រើចំនួនប្រជាជនគោលដៅដែលបានចុះឈ្មោះ ដោយចងចាំថា៖ ១) ប្រជាជនម្នាក់ត្រូវការវ៉ាក់សាំង ២ដូស និង២) អត្រាខាតបង់នៃវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈ-បរិក្ខារដែលត្រូវការគឺ ១៥%
  - បើការចុះឈ្មោះពុំទាន់ចប់សព្វគ្រប់ទេ ប៉ាន់ប្រមាណចំនួនដូសដោយប្រើចំនួនប៉ាន់ស្មាននៃប្រជាជនគោលដៅដោយប្រើជំរឿន ឬស្ថិតិរបស់រដ្ឋបាលមូលដ្ឋាន និងដោយប្រើការសន្មតដូចខាងលើ។
- គ្រប់គ្រងដោយប្រសិទ្ធភាពវ៉ាក់សាំង និងការផ្គត់ផ្គង់ផ្សេងៗ ដែលរក្សាទុកបន្ទាប់ពីទទួលបានពីមន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមចាក់វ៉ាក់សាំង
- ធានាថា រាល់ប៉ុស្តិ៍ចាក់វ៉ាក់សាំងទាំងអស់មានការផ្គត់ផ្គង់វ៉ាក់សាំង និងសម្ភារៈ-បរិក្ខាផ្សេងៗ គ្រប់គ្រាន់ទៅតាមចំនួនប្រជាជនគោលដៅ
- ប្រមែប្រមូលធនធានមនុស្ស (អ្នកចាក់វ៉ាក់សាំង) ដែលត្រូវការពីមូលដ្ឋានសុខាភិបាលផ្សេងទៀត
- នៅចុងបញ្ចប់នៃថ្ងៃនីមួយៗ ស្រុកប្រតិបត្តិត្រូវសួរនាំប្រធានក្រុមទាំងអស់ពីការបំពេញការងារ (ការគ្របដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈ-បរិក្ខារផ្សេងទៀត) និងប្រាកដថា សកម្មភាពកែតម្រូវត្រូវបានធ្វើ បើចាំបាច់
- ត្រូវប្រាកដថា ប្រអប់សុវត្ថិភាពដែលពេញត្រូវបានប្រមូលនិងរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព និងត្រូវបានបញ្ជូនទៅកន្លែងដុត (ឡដុត) ដែលត្រូវបានកំណត់ ជារៀងរាល់ថ្ងៃ
- ធានាថា បានរាយការជាបន្ទាន់ទៅមន្ទីរសុខាភិបាល ក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងនឹង៖
  - ហេតុការកើតមានក្រោយការផ្តល់ថ្នាំបង្ការធ្ងន់ធ្ងរ និងបញ្ជូនទៅត្រួតពិនិត្យបន្តនៅមន្ទីរពេទ្យ
  - ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈ-បរិក្ខារផ្សេងទៀត ក្នុងអំឡុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ត្រូវប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំង និងតុល្យការស្តុក ទៅមន្ទីរសុខាភិបាល មិនឱ្យហួសបីថ្ងៃបន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវបានបញ្ចប់។

## ៦.៧. តួនាទី និងការទទួលខុសត្រូវរបស់មន្ទីរសុខាភិបាលរាជធានី-ខេត្ត

- បូកសរុបការប៉ាន់ប្រមាណចំនួនដូសនៃវ៉ាក់សាំងកូវីដ-១៩ ដែលត្រូវការសម្រាប់ស្រុកប្រតិបត្តិនីមួយៗ
- គ្រប់គ្រងដោយប្រសិទ្ធិភាពវ៉ាក់សាំង និងការផ្គត់ផ្គង់ផ្សេងៗ ដែលរក្សាទុកបន្ទាប់ពីទទួលពីឃ្លាំងឱសថកណ្តាលក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ធានាដល់សន្តិសុខ និងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមចាក់វ៉ាក់សាំង
- ធានាថា ស្រុកប្រតិបត្តិទាំងអស់មានការផ្គត់ផ្គង់វ៉ាក់សាំង និងសម្ភារៈ-បរិក្ខារគ្រប់គ្រាន់តាមចំនួនប្រជាជនគោលដៅ
- ប្រមែប្រមូលធនធានមនុស្ស (អ្នកចាក់វ៉ាក់សាំង) ដែលត្រូវការពីមូលដ្ឋានសុខាភិបាលផ្សេងទៀត
- នៅចុងបញ្ចប់នៃថ្ងៃនិមួយៗ មន្ទីរសុខាភិបាលរាជធានី-ខេត្តត្រូវសួរនាំស្រុកប្រតិបត្តិអំពីការបំពេញការងារ (ការគ្របដណ្តប់នៃការចាក់វ៉ាក់សាំង តុល្យការស្តុកវ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈ-បរិក្ខារ) និងប្រាកដថា សកម្មភាពកែតម្រូវត្រូវបានធ្វើ បើចាំបាច់

- ធានាថា បានរាយការជាបន្ទាន់ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ក្នុងករណីមានបញ្ហាណាមួយដែលទាក់ទងនឹង៖
  - ហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង៖ គាំទ្រមន្ទីរពេទ្យក្នុងការពិនិត្យ-ព្យាបាលសង្គ្រោះបន្ទាន់ និងជម្រាបជូនទៅគណៈកម្មការខេត្តប្រយុទ្ធនឹងកូវីដ-១៩
  - ការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ និងសម្ភារៈ-បរិក្ខារផ្សេងទៀត ក្នុងអំឡុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ត្រូវប្រគល់របាយការណ៍អំពីការប្រើប្រាស់វ៉ាក់សាំងនិងតុល្យការស្តុក ទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការ មិនឱ្យហួសប្រាំថ្ងៃ បន្ទាប់ពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវបានបញ្ចប់។

### ៦.៨. តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលមូលដ្ឋាន

- សម្របសម្រួល ការត្រៀមរៀបចំ សម្រាប់យុទ្ធនាការចាក់វ៉ាក់សាំង
- សម្របសម្រួលនីតិវិធីចុះឈ្មោះប្រជាជនគោលដៅជាមុន
- សម្របសម្រួលនៅកន្លែងចាក់វ៉ាក់សាំង ដោយរៀបចំចរន្តអតិថិជន រក្សាគម្លាតរូបវន្ត និងជៀសវាងផ្តុំគ្នា។
- ធានាដល់សន្តិសុខនិងសុវត្ថិភាពនៃការរក្សាទុកវ៉ាក់សាំង និងក្រុមចាក់វ៉ាក់សាំង
- គាំទ្រនិងធានាដល់សុវត្ថិភាពមន្ត្រីសុខាភិបាលដែលចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ (ចាក់វ៉ាក់សាំង រក្សាទុកដាក់វ៉ាក់សាំង អង្កេតស្រាវជ្រាវហេតុការកើតមានក្រោយការចាក់វ៉ាក់សាំង ការគាំទ្រផ្នែកយុត្តាធិការក្នុងករណីមានហេតុការធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង...)
- គាំទ្រដល់ការកៀរគរ-ប្រមែប្រមូលប្រជាជនគោលដៅដើម្បីចាក់វ៉ាក់សាំង
- គាំទ្រដល់ការប្រាស្រ័យទាក់ទងពីហានិភ័យ។

## ៧. ការគ្រប់គ្រងបរិក្ខារប្រព័ន្ធត្រជាក់ និងវ៉ាក់សាំង

ប្រទេសកម្ពុជាមានប្រព័ន្ធផ្គត់ផ្គង់រឹងមសម្រាប់ការងារផ្តល់ថ្នាំបង្ការជាប្រចាំ រួមទាំងបទពិសោធន៍ក្នុងការគ្រប់គ្រងយុទ្ធនាការផ្តល់ថ្នាំបង្ការ តាំងពីការលុបបំបាត់ជំងឺគ្រុនស្វិតដៃជើងមកម្លេះ។

### ៧.១. គន្លឹះសំខាន់ៗអំពីសមត្ថភាពស្តុកទុកវ៉ាក់សាំងកូវីដ-១៩

- យោងតាមការវាយតម្លៃនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ មូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់មានសមត្ថភាពរក្សាទុកដាក់វ៉ាក់សាំងរឹងមាំ ដែលអាចទទួលបន្ថែមវ៉ាក់សាំងកូវីដ-១៩។ បើមានបញ្ហាពីសមត្ថភាពរក្សាទុក ឬបើមានទូវ៉ាក់សាំងខូច មណ្ឌលសុខភាពនិងការិយាល័យស្រុកប្រតិបត្តិ ត្រូវរាយការជូនថ្នាក់លើបន្ទាប់ភ្លាមៗ និងត្រូវរៀបចំកន្លែងរក្សាទុកផ្សេងទៀតដែលអាចមានឱ្យបានឆាប់រហ័ស។
- បរិមាណវ៉ាក់សាំងដែលត្រូវបានបែងចែងសម្រាប់មណ្ឌលសុខភាពនីមួយៗ នឹងអាស្រ័យជាជាចម្បងលើទិន្នន័យនៃសម្រង់ប្រជាជនគោលដៅជាមុន និងកាលវិភាគនៃការចាក់វ៉ាក់សាំងដូចក្នុងផែនការលំអិត។
- សំភារៈបរិក្ខា ដូចជាស៊ីរ៉ាំងនិងប្រអប់សុវត្ថិភាពនឹងត្រូវបានបែងចែកជាមួយវ៉ាក់សាំង។
- វ៉ាក់សាំងកូវីដ-១៩ គួរត្រូវបានរក្សារទុក និងដឹកជញ្ជូនក្នុងស៊ីតុណ្ហភាពសមស្រប ចន្លោះ +២ ទៅ +៨ អង្សាសេ។
- ប្រអប់កក-ប្រអប់ត្រជាក់ដែលត្រូវការសម្រាប់យុទ្ធនាការ គួរត្រូវបានគណនាបរិមាណនិងរៀបចំ ទុកជាមុន។ ធ្វើការពិនិត្យប្រអប់កក (រកមើលលេចឬប្រេះឆ្នុក) និងជ្រើសរើសយកតែប្រអប់កក-ប្រអប់ត្រជាក់ដែលល្អមកប្រើ។
- បើវ៉ាក់សាំងកូវីដ-១៩ ជាវត្ថុរាវ មិនត្រូវឱ្យវាកកទេ ព្រោះអាចធ្វើបាត់សក្តានុពលរបស់វ៉ាក់សាំង ហើយវាមិនមានអាចការពារប្រឆាំងនឹងជំងឺកូវីដ-១៩ ទេ។

### ៧ -២- របាយការណ៍វ៉ាក់សាំង និងសំភារៈ

ក្រុមចាក់វ៉ាក់សាំងកូវីដ-១៩ របស់មូលដ្ឋានសុខាភិបាលត្រូវរៀបចំរបាយការណ៍ស្តីពីការផ្គត់ផ្គង់ (វ៉ាក់សាំងនិងភ័ស្តុភារ) ឱ្យបានត្រឹមត្រូវនិងប្រចាំថ្ងៃ។

- របាយការណ៍វ៉ាក់សាំងនិងភ័ស្តុភារនេះគួរត្រូវបានផ្ញើពីមូលដ្ឋានសុខាភិបាលទៅស្រុកប្រតិបត្តិរៀងរាល់ថ្ងៃ បន្ទាប់ពីបាន បញ្ចប់ការចាក់វ៉ាក់សាំងនៃថ្ងៃនិមួយៗ។
- ស្រុកប្រតិបត្តិនឹងពិនិត្យរបាយការណ៍ រួចបញ្ជូនទៅមន្ទីរសុខាភិបាលខេត្តក្នុងថ្ងៃដដែល។
- មន្ទីរសុខាភិបាលខេត្តពិនិត្យនិងផ្តុំរបាយការណ៍ស្រុកប្រតិបត្តិ រួចផ្ញើទៅកម្មវិធីជាតិផ្តល់ថ្នាំបង្ការក្នុងថ្ងៃដដែល។

## ៨. ការចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព និងសុវត្ថិភាព

កម្មវិធីជាតិផ្តល់ថ្នាំបង្ការធ្លាប់បានប្រើប្រាស់ដោយជោគជ័យ ស៊ីរ៉ាំង AD និងប្រអប់សុវត្ថិភាព សម្រាប់កម្មវិធីផ្តល់ថ្នាំបង្ការជាប្រចាំ និងយុទ្ធនាការផ្តល់ថ្នាំបង្ការ ហើយមន្ត្រីកម្មវិធីទាំងអស់សុទ្ធតែមានបទពិសោធន៍គ្រប់គ្រាន់។

### ៨.១. ការចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព

សម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ស៊ីរ៉ាំង AD ចំណុះ ០.៥ ម.ល នឹងត្រូវបានប្រើប្រាស់។ អត្រាខាតបង់ស៊ីរ៉ាំងមានប្រមាណ ១០%។ ក្នុងការគណនាតម្រូវការក្នុងអំឡុងពេលធ្វើផែនការលំអិត មន្ត្រីសុខាភិបាលគួរប្រើអត្រាខាតបង់នេះ។

**គន្លឹះក្នុងការចាក់វ៉ាក់សាំងប្រកបដោយសុវត្ថិភាព**

- ធានាថាមានស៊ីរ៉ាំង AD និងប្រអប់សុវត្ថិភាព ព្រមទាំងថ្នាំបង្ការគ្រប់គ្រាន់ (មើលលេខ ៧.២ ខាងលើបើវ៉ាក់សាំងពុំមានសម្ភារៈភ្ជាប់មកជាមួយ)
- មិនត្រូវប៉ះគម្របជ័រនៃដបវ៉ាក់សាំងកូវីដ-១៩ ទេ ក្រៅពីម្ជុលដែលបើកថ្មី និងស៊ីរ៉ាំង AD ដែលមិនទាន់ប្រើ (បើមានប៉ះជាមួយវត្ថុផ្សេងទៀត ត្រូវចោលដបវ៉ាក់សាំងកូវីដ-១៩ នោះ)
- បូមវ៉ាក់សាំងកូវីដ-១៩ ដោយប្រើស៊ីរ៉ាំង AD បើមានវត្តមានអ្នកទទួលនៅទីនោះ មិនត្រូវបូមវ៉ាក់សាំងដាក់ក្នុងស៊ីរ៉ាំង AD ទុកជាមុន។
- ធានាដល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រឹមត្រូវ ដោយជ្រើសរើសវិធីចាក់ និងទីកន្លែងចាក់ត្រឹមត្រូវ។

### ៨.២. ការគ្រប់គ្រងសំណល់

- មូលដ្ឋានសុខាភិបាលត្រូវធានាថា ក្រុមចាក់វ៉ាក់សាំងនិមួយៗ មានស៊ីរ៉ាំង AD និងប្រអប់សុវត្ថិភាពគ្រប់គ្រាន់ ដាក់ទៅក្នុងប្រអប់សុវត្ថិភាពតែស៊ីរ៉ាំង AD ស៊ីរ៉ាំងលាយ ម្ជុល និងគម្របម្ជុលតែប៉ុណ្ណោះ
- មិនត្រូវបំពេញប្រអប់សុវត្ថិភាពឱ្យលើសពីបីភាគបួននៃចំណុះរបស់វាទេ
- បិតឱ្យជិតល្អប្រអប់សុវត្ថិភាពដែលពេញ ប្រមូលផ្តុំ និងទុកដាក់ឱ្យបានត្រឹមត្រូវនៅចុងបញ្ចប់នៃការចាក់វ៉ាក់សាំងរាល់ថ្ងៃនៅមូលដ្ឋានសុខាភិបាល មុននឹងបញ្ជូនទៅកន្លែងទុកដាក់សំណល់នៃការចាក់ថ្នាំបង្ការដែលបានកំណត់
- មណ្ឌលសុខភាព-ស្រុកប្រតិបត្តិត្រូវរៀបចំដឹកជញ្ជូនប្រអប់សុវត្ថិភាពដែលពេញរួច ទៅកន្លែងដែលមានឡដុតដែលមានសីតុណ្ហភាពខ្ពស់ ឬឡកំទេចតាមបច្ចេកវិទ្យាថ្មីដើម្បីកំទេចចោល។

## ៩. ការប្រាស្រ័យទាក់ទងពីហានិភ័យ និងការកៀរគរសង្គម

ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពរួមមានការប្រាស្រ័យទាក់ទងរវាងបុគ្គលនិងបុគ្គលព្រមទាំងការកៀងគរសង្គមមានសារៈសំខាន់ណាស់ក្នុងការធានាថាប្រជាជនគោលដៅមិនត្រូវបានខកខានក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។

មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព ដោយមានកិច្ចសហការជិតស្និតជាមួយជនបង្គោលសម្រាប់ប្រាស្រ័យទាក់ទងពីហានិភ័យនៃក្រសួងសុខាភិបាល និងអនុក្រុមប្រាស្រ័យទាក់ទងនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ កំពុងអភិវឌ្ឍសារអប់រំ សម្ភារៈអប់រំទាំងបោះពុម្ព និងអេឡិកត្រូនិក សម្រាប់ផ្សព្វផ្សាយជាសាធារណៈ ពិសេសការប្រាស្រ័យទាក់ទងពីហានិភ័យសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីលើកកម្ពស់ការយល់ដឹងនិងការចូលរួមរបស់សហគមន៍។

សកម្មភាពខាងក្រោមនឹងត្រូវធ្វើមុននិងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព កម្មវិធីជាតិផ្តល់ថ្នាំបង្ការ មន្ទីរសុខាភិបាលរាជធានី-ខេត្ត ស្រុកប្រតិបត្តិ និង រដ្ឋបាលមូលដ្ឋាន៖

- យុទ្ធនាការផ្សព្វផ្សាយតាមទូរទស្សន៍-វិទ្យុពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនព័ត៌មានដល់ប្រជាជនគោលដៅ
- សន្និសីទសារព័ត៌មានថ្នាក់ជាតិដើម្បីផ្សព្វផ្សាយសារស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩
- ការប្រជុំកៀរគរការគាំទ្រ ជាមួយគណៈវិជ្ជាជីវៈជំនាញមុនពេលធ្វើយុទ្ធនាការ
- ការប្រកាសជាផ្លូវការ យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ មុនពេលចាប់ផ្តើមយុទ្ធនាការ ដើម្បីផ្សព្វផ្សាយសារឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់
- ការដាក់តាំងផ្ទាំងបដានិងផ្ទាំងរូបភាពមុនថ្ងៃចាក់វ៉ាក់សាំង ដើម្បីបញ្ជូនសារសំខាន់ៗទៅប្រជាជនគោលដៅ
- ការប្រាស្រ័យទាក់ទងអន្តរបុគ្គល និងការកៀរគរសង្គម ដោយមន្ត្រីសុខាភិបាលនិងអ្នកពាក់ព័ន្ធផ្សេងទៀត
- ផ្សព្វផ្សាយសារតាមឧបករណ៍បំពងសម្លេងចល័ត អំពីយុទ្ធនាការចាក់វ៉ាក់សាំង នៅតាមមណ្ឌលសុខភាពនីមួយៗ
- ចែករំលែកព័ត៌មានត្រឹមត្រូវដល់សាធារណជនឱ្យបានទាន់ពេលវេលា ដើម្បីធានាថាសាធារណជនយល់ដឹង និងគាំទ្រយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ និង សុវត្ថិភាពវ៉ាក់សាំង
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពផ្តល់ពត៌មានមកកម្មវិធីជាតិ អំពីការយល់ឃើញអវិជ្ជមានចំពោះវ៉ាក់សាំងនិងពាក្យចចាមអារ៉ាម
- អភិបាលស្រុក ខណ្ឌ ក្រុង ក្រុមប្រឹក្សាឃុំ-សង្កាត់ មេភូមិ និងក្រុមទ្រទ្រង់សុខភាពភូមិ នឹងជូនដំណឹងទៅសាធារណៈជន និងកៀរគរការគាំទ្រសហគមន៍ដល់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩។

## ១០. ការអភិបាល និងតាមដាន

- អ្នកសម្របសម្រួលថ្នាក់ខេត្ត (២-៥ នាក់ក្នុង១ខេត្ត) នឹងត្រូវចាត់ឱ្យសម្របសម្រួលយុទ្ធនាការចាក់វ៉ាក់សាំងជាមួយប្រធានក្រុមចាក់វ៉ាក់សាំង
- អ្នកសម្របសម្រួលថ្នាក់ជាតិដែលមានសមាជិក ២៥ នាក់នឹងត្រូវបានចាត់ទៅខេត្តនីមួយៗ និងធ្វើការងារជាមួយអ្នកសម្របសម្រួលថ្នាក់ខេត្ត និងប្រធានក្រុម
- ប្រធានក្រុម និងអ្នកសម្របសម្រួលទាំងអស់នឹងត្រូវប្រើបញ្ជីផ្ទៀងផ្ទាត់ស្តង់ដារនៅពេលចុះអភិបាលកន្លែងចាក់វ៉ាក់សាំង និងផ្តល់ការគាំទ្រក្រុមចាក់វ៉ាក់សាំង។

ការគ្រប់គ្រងទិន្នន័យត្រឹមត្រូវក្នុងអំឡុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ចាំបាច់ណាស់ដើម្បីតាមដានវឌ្ឍនភាព។ បញ្ជីអ្នកបានទទួលវ៉ាក់សាំង និងអត្រាគ្របដណ្តប់អាចត្រូវបានទាញចេញពីកម្មវិធី។ មូលដ្ឋានសុខាភិបាលអាចទាញយកនៅចុងបញ្ចប់នៃថ្ងៃចាក់វ៉ាក់សាំងនីមួយៗសម្រាប់រក្សាទុកឯកសារ និងត្រៀមចាក់វ៉ាក់សាំងដូសទី២។

## ១១. ការពិនិត្យ និងគ្រប់គ្រងហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង

វ៉ាក់សាំងកូវីដ-១៩ ជាវ៉ាក់សាំងមានសុវត្ថិភាព និងប្រសិទ្ធភាព។ ដូចវ៉ាក់សាំងដទៃទៀតដែរ វ៉ាក់សាំងកូវីដ-១៩ អាចបង្កឱ្យមានប្រតិកម្មមួយចំនួន។ ក្រុមចាក់វ៉ាក់សាំង ក្រុមអ្នកអភិបាល ក្រុមសម្របសម្រួលត្រូវធានាថា មានការស្រាវជ្រាវរក ការកត់ត្រា និងការរាយការត្រឹមត្រូវរាល់ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង បើមាន និងត្រូវផ្តល់ការគាំទ្រដល់ការគ្រប់គ្រងករណី។ ក្នុងករណីដែលមានហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំងកូវីដ-១៩ បញ្ជូនទៅផ្នែកសង្គ្រោះបន្ទាន់ភ្លាម។

### ១១.១. និយមន័យនៃហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង

ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង ជាហេតុការណ៍វេជ្ជសាស្ត្រណាមួយកើតឡើងបន្ទាប់ពីការចាក់វ៉ាក់សាំង ដែលមិនចាំបាច់មានទំនាក់ទំនងហេតុផលជាមួយនឹងការចាក់វ៉ាក់សាំងទេ។ ហេតុការណ៍នេះអាចជាស្តែងចេញជាសញ្ញាមិនសុខស្រួល ឬដែលរំខាន ភាពមិនប្រក្រតីនៃលទ្ធផលមន្ទីរពិសោធន៍ ឬជាចង្កោមរោគសញ្ញា ឬជាជំងឺ។

## ១១.២. ការរាយការណ៍អំពីហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង

ខេត្តនីមួយៗនឹងបង្កើតគណៈកម្មការគ្រប់គ្រងហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង សម្រាប់គ្រប់គ្រងករណីហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង។ ខេត្តនីមួយៗនឹងបង្កើតក្រុមបច្ចេកទេសខេត្តសម្រាប់អង្កេតស្រាវជ្រាវហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងដែលបានរាយការ។ សម្រាប់ការរាយការ និងការអង្កេតស្រាវជ្រាវហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងក្នុងអំឡុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្រុមអ្នកអង្កេតស្រាវជ្រាវនឹងប្រើគម្រូបាយការណ៍ និងទម្រង់សម្រាប់អង្កេតស្រាវជ្រាវហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងជាប្រចាំដែលមានស្រាប់។

កញ្ចប់សង្គ្រោះបន្ទាន់សម្រាប់ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំង ត្រូវបានផ្តល់ជូនក្នុងអំឡុងពេលយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នៅមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព។ មន្ទីរសុខាភិបាលខេត្តនិងស្រុកប្រតិបត្តិនីមួយៗ ត្រូវសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយមូលដ្ឋានសុខាភិបាលក្នុងការគ្រប់គ្រងសង្គ្រោះបន្ទាន់។

មន្ទីរពេទ្យទាំងអស់នឹងត្រូវបំពាក់កញ្ចប់សង្គ្រោះបន្ទាន់ (មើល១១.៣)។ បើមានហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំងក្នុងអំឡុងយុទ្ធនាការ ត្រូវបញ្ជូនអ្នកជំងឺជាបន្ទាន់ទៅផ្នែកសង្គ្រោះបន្ទាន់ និងរាយការទៅអ្នកសម្របសម្រួលរាជធានី-ខេត្ត។ រដ្ឋបាលមូលដ្ឋាន មេភូមិ អ្នកស្ម័គ្រចិត្តត្រូវរាយការទៅមណ្ឌលសុខភាពរាល់ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងដែលកើតឡើងបន្ទាប់ពីប្រជាពលរដ្ឋដែលបានចាក់វ៉ាក់សាំងរួចត្រឡប់ទៅផ្ទះវិញ។ មណ្ឌលសុខភាពនឹងរាយការបន្តជាបន្ទាន់ទៅអ្នកសម្របសម្រួលរាជធានី-ខេត្ត តាមរយៈស្រុកប្រតិបត្តិ ព្រមទាំងជួយរៀបចំបញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ។ រថយន្តគិលានសង្គ្រោះត្រូវបានត្រៀមបម្រុងរួចជាស្រេចនៅមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ និងមណ្ឌលសុខភាពមួយចំនួន និងអាចប្រើប្រាស់សម្រាប់ការបញ្ជូនភ្លាម បើត្រូវការ។

- រាល់ហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំងរួច និងករណីផ្សេងទៀតនឹងត្រូវបានបញ្ជូនទៅថ្នាក់ជាតិដើម្បីពិនិត្យឡើងវិញដោយគណៈកម្មការជំនាញ និងដើម្បីវាយតម្លៃពីមូលហេតុ
- គណៈកម្មការខេត្តប្រយុទ្ធនឹងជំងឺកូវីដ-១៩ នឹងសម្របសម្រួលដល់ការអង្កេតស្រាវជ្រាវ គ្រប់គ្រងករណី និងប្រាស្រ័យទាក់ទងពីហានិភ័យ
- ឱសថដែលត្រូវការសម្រាប់គ្រប់គ្រង-ព្យាបាលករណីហេតុការណ៍កើតមានក្រោយការផ្តល់ថ្នាំបង្ការ ត្រូវមានជាស្រេចមុនចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងនៅមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត និង មន្ទីរពេទ្យបង្អែក។

បន្ទាប់ពីគ្រប់គ្រងហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង (បញ្ជូនទៅផ្នែកសង្គ្រោះបន្ទាន់) ករណីកើតមានក្រោយការចាក់វ៉ាក់សាំងគួរត្រូវបានរាយការទៅតាមគោលការណ៍ណែនាំជាតិ។ មន្ត្រីសុខាភិបាលត្រូវរាយការជាបន្ទាន់ហេតុការណ៍ធ្ងន់ធ្ងរណាមួយតាមទូរស័ព្ទភ្លាមបន្ទាប់ពីស្រាវជ្រាវរកឃើញ។ មន្ត្រីសុខាភិបាលត្រូវរាយការពីហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងដែលបានស្រាវជ្រាវរកឃើញ ដូចតទៅ៖

- រាល់ករណីហេតុការណ៍ធ្ងន់ធ្ងរកើតមានក្រោយការចាក់វ៉ាក់សាំង
- ហេតុការណ៍ដែលគំរាមកំហែងដល់អាយុជីវិត ឬដែលឈានដល់សេចក្តីស្លាប់ ដែលចូលសម្រាកក្នុងមន្ទីរពេទ្យ ដែលអាចមានពិការភាពជាក់លាក់ ឬវិការភាពពីកំណើត
- ធ្លាប់មានប្រតិកម្មដែលមិនស្គាល់ពីមុនមក (សញ្ញា)
- ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងជាក្រុម (រួមទាំងករណីស្រាល)
- រាល់ហេតុការណ៍ដែលធ្វើឱ្យសហគមន៍មានការបារម្ភខ្លាំង
- ហេតុការណ៍កើតមានក្រោយការចាក់វ៉ាក់សាំងទម្រង់ស្រាល៖ ហើម ឡើងក្រហម ឈឺនៅកន្លែងចាក់ បើវាមានរយៈពេលលើស ៣ថ្ងៃ ឬបើហើមរាលដាលដល់តំបន់ជិតខាងនៃសន្លាក់នៅជិតបំផុត។

## ១១.៣. សម្ភារបរិក្ខាសម្រាប់កញ្ចប់ឃីត ហេតុការណ៍កើតមានក្រោយការផ្តល់ថ្នាំបង្ការ:

### សម្ភារបរិក្ខាដែលចាំបាច់ត្រូវតែមាន៖

- Adrenaline (១: ១,០០០ក្នុង១ម.ល= ១ ម.ក/១ ម.ល) ១ អំពូល

- Adrenaline (១: ១០,០០០= ១ ម.ក/១០ ម.ល) ២ អំពូល
- កញ្ចប់សំឡីអាកុលសំរាប់ជូតសម្លាប់មេរោគ ២ សន្លឹក
- ស៊ីរ៉ាំងចំណុះ ១ ម.ល ចំនួន ២
- ម្ជុលលេខ ១៨ ឬ ១៩ ក្រ ចំនួន ២
- ម្ជុលលេខ ២៣ ក្រ x ៣២ ម.ម ចំនួន១
- តារាងណែនាំកម្រិតប្រើថ្នាំ Adrenaline (ឬថ្នាំ Epinephrine) ដែលត្រូវបានអ៊ុតប្លាស្ទិក

**សម្ភារបរិក្ខារបន្ថែម៖**

- Antihistamines
- Steroids
- សេរ៉ូម Dextrose (50%) ampules
- សេរ៉ូមប្រៃធម្មតា Normal Saline
- ឧបករណ៍សង្គ្រោះដង្ហើម
- ម៉ាសហោប៉ាវ
- ស្តេតូស្កុប និង ប្រដាប់វាស់សម្ពាធឈាម
- ប្រដាប់សង្កត់អណ្តាត / កន្ត្រៃ
- ខ្សែបង្ហូរសេរ៉ូម និងសម្ភារៈដែលត្រូវការផ្សេងទៀត ដូចជាឧបករណ៍ចងរឹតដៃ
- ខ្យល់អុកស៊ីហ្សែន និងឧបករណ៍ដែលត្រូវការដើម្បីផ្តល់អុកស៊ីហ្សែន

សម្រាប់ការគ្រប់គ្រងព្យាបាលប្រតិកម្មអាណាហ្វីឡាក់ស៊ី ការប្រាស្រ័យទាក់ទងដែលមានប្រសិទ្ធភាព ការគ្រប់គ្រងវិបត្តិ និងបញ្ហាផ្សេងទៀត សូមប្រើ "គោលការណ៍ណែនាំប្រតិបត្តិសម្រាប់ការតាមដានហេតុការណ៍កើតមានក្រោយការផ្តល់ថ្នាំបង្ការ"។

## ១២. ផែនការបម្រុងយថាហេតុ

ក្រសួងសុខាភិបាលបានរៀបចំផែនការបម្រុងសម្រាប់យថាហេតុ ដូចខាងក្រោម៖

- ការកំណត់រកផ្នែកឯកជនដែលមានសមត្ថភាពរក្សាទុកនិងដឹកជញ្ជូនវ៉ាក់សាំងកំពុងត្រូវបានធ្វើ។ កិច្ចព្រមព្រៀងអំពីការផ្តល់សេវារក្សាទុកនិងដឹកជញ្ជូនវ៉ាក់សាំងកូវីដ-១៩ នឹងត្រូវបានរៀបចំ។ បើបរិមាណវ៉ាក់សាំងកូវីដ-១៩ ដែលមកដល់កម្ពុជាមានចំនួនលើសសមត្ថភាពរក្សាទុកនិងដឹកជញ្ជូនរបស់ក្រសួងសុខាភិបាល ដោយមកពីវ៉ាក់សាំងដែលមកដល់មានបរិមាណច្រើន និងមកច្រើនជើងផ្ទួនៗ ក្នុងរយៈពេលដ៏ខ្លី នោះក្រសួងសុខាភិបាលនឹងប្រើប្រាស់ ផ្នែកសេវាឯកជនដើម្បីផ្តល់សេវារក្សាទុកនិងដឹកជញ្ជូនវ៉ាក់សាំង។
- ក្នុងអំឡុង និងមុនបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំង ក្រសួងសុខាភិបាល កម្មវិធីជាតិផ្តល់ថ្នាំបង្ការ មន្ទីរសុខាភិបាលរាជធានី-ខេត្ត និងស្រុកប្រតិបត្តិ នឹងធ្វើការវាយតម្លៃស្ថានភាពនៃការគ្របដណ្តប់របស់ការចាក់វ៉ាក់សាំង៖
  - ក្នុងករណីដែលការគ្របដណ្តប់មានកម្រិតទាប ការកៀរគរសង្គម និងការប្រាស្រ័យទាក់ទងផ្សេងទៀតនឹងត្រូវបានប្រើប្រាស់ ដើម្បីលើកទឹកចិត្តដល់ការមកចាក់វ៉ាក់សាំងកូវីដ-១៩
  - រដ្ឋបាលមូលដ្ឋាននឹងត្រូវបានស្នើសុំឱ្យជួយក្នុងការកំណត់រក អ្នកដែលខកខានមិនបានចាក់វ៉ាក់សាំង ឱ្យមកចាក់វ៉ាក់សាំងនៅមូលដ្ឋានសុខាភិបាលដែលនៅជិតគាត់បំផុត។
- នៅចុងបញ្ចប់នៃយុទ្ធនាការ ធ្វើបច្ចុប្បន្នភាពស្ថានភាពនៃវ៉ាក់សាំងកូវីដ-១៩ និងការផ្គត់ផ្គង់ផ្សេងទៀត (ស៊ីរ៉ាំងអេឌី ប្រអប់សុវត្ថិភាព)។ គ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវរាយការ និងបញ្ជូនត្រឡប់ទៅឃ្លាំងឱសថកណ្តាលវិញនូវរាល់វ៉ាក់សាំងកូវីដ-១៩ និងការផ្គត់ផ្គង់ផ្សេងទៀតដែលនៅសល់។ ការប្រើប្រាស់វ៉ាក់សាំងកូវីដ-១៩ និងការផ្គត់ផ្គង់ផ្សេងទៀតដែលនៅសល់អាស្រ័យនឹងការសម្រេចចិត្តរបស់ក្រសួងសុខាភិបាល។

## ១៣. ការបញ្ចប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩

ការវាយតម្លៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នឹងត្រូវបានធ្វើឡើងដោយកម្មវិធីជាតិផ្តល់ថ្នាំបង្ការ និងដៃគូនានា ហើយរបាយការណ៍បញ្ចប់ប្រតិបត្តិការនៃយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នឹងត្រូវបានរៀបចំឡើងបន្ទាប់ពីការវាយតម្លៃក្រោយយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ បានបញ្ចប់។

មេរៀនទទួលបាន ភាពខ្លាំង និងភាពខ្សោយ រួមបញ្ចូលទាំងរបាយការណ៍នៃការគ្រប់ដណ្តប់តាមក្រុមប្រជាជនគោលដៅ ការទុកដាក់ជាឯកសារនូវរាល់ធនធានដែលត្រូវបានប្រើប្រាស់ឬមិនបានប្រើប្រាស់នៅក្នុងសមាសភាគភាគច្រើន នឹងត្រូវបានកត់ត្រា។ របាយការណ៍នេះមានសារៈប្រយោជន៍សម្រាប់យុទ្ធនាការនាអនាគត និងដើម្បីធានាផងដែរថា បទពិសោធន៍ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ នឹងត្រូវបានប្រើប្រាស់ដើម្បីពង្រឹងបន្ថែមទៀតកម្មវិធីផ្តល់ថ្នាំបង្ការដែលរឹងមាំស្រាប់នៅកម្ពុជា។